# លក្ខន្តិកៈ

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)

### ជំពូកទី ១

### បទបញ្ញត្តិទូទៅ

**ប្រការ ១ : ទម្រង់គតិយុត្ត និងឈ្មោះ**

អនុលោមតាម :

- ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

- អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ

- ផែក្រុងព្រះសីហនុ ត្រូវបានកំណត់នាមថា : **កំពង់ផែស្វយ័តក្រុងព្រះសីហនុ** សរសេរជាអក្សរកាត់ " **កសស** " ជាភាសាបារាំង ( PORT AUTONOME DE SIHANOUKVILLE ) សរសេរអក្សរកាត់ ( **PAS** )។

**ប្រការ ២ : ភារកិច្ច និងគោលដៅ**

**កសស** មានភារកិច្ចធ្វើអាជីវកម្ម និងសេវាកម្មជាមូលដ្ឋានលើការងារ :

- កណ្តាធារកិច្ចនាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ ផ្ទេរផ្ទុក និងដឹកជញ្ជូនទំនិញ
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំង-ទីលាន
- ការងារអភិវឌ្ឍន៍ និងស្តារហេដ្ឋារចនាសម្ពន្ធ័ **កសស** ដែលមាន ដែលត្រូវពង្រីក
- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង
- ប្រកាន់គោលការណ៏ និងរបៀបកិច្ចការដូចគ្នា នឹងអាជីវករ ។
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពអោយមានប្រសិទ្ធភាព និងមានការរីកចំរើន
- ក្នុងឋានៈជាស្ថាប័នសាធារណៈ **កសស** ទទួលពីរដ្ឋនូវអំណាច និងកាតព្វកិច្ចទាំងឡាយដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

**ប្រការ ៣ : ទីចាត់ការ**

ទីចាត់ការរបស់ **កសស** មានទីចាត់ការស្ថិតនៅតាមវិថីផែ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ។ ការផ្លាស់ប្តូរទីចាត់ការទៅកាន់ទីតាំងផ្សេងទៀតត្រូវសំរេចដោយក្រុមប្រឹក្សាភិបាល និងមានការបញ្ជាក់យល់ព្រមពី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលមានសិទ្ធិសំរេចលើការបើក ឬការបិទគ្រប់សាខា ទីភ្នាក់ងារ ឬតំណាងទាំងអស់ដែលចាំបាច់ដល់ការអនុវត្តន៍អោយសំរេចភារកិច្ចរបស់ **កសស** ។

**ប្រការ ៤ : ថិរវេលា**

**កសស** ធ្វើសកម្មភាពពុំមានពេលកំណត់ លើកលែងក្នុងករណីដែលមានការរំសាយ ការប្តូរទ្រង់ទ្រាយ ការរំលាយបញ្ចូលគ្នា ឬការបំបែក ដោយសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៥ : អាណាព្យាបាល**

**កសស** ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២
## មូលធនរបស់ កសស

**ប្រការ ៦ : មូលធន**

មូលធនដំបូងនៃ **កសស** មានចំនួន **372.185.464.602,33** រៀល ដែលបានកំណត់ដោយបញ្ជីតុល្យការចាប់ផ្តើមដែលបានទទួលការឯកភាពពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៧ : ការបន្ថែមមូលធន**

ការបន្ថែមមូលធនត្រូវសំរេចដោយក្រុមប្រឹក្សាភិបាល ។

ការបន្ថែមមូលធនអាចជាភាគទុនរូបិយវត្ថុ ភាគទុនជាទ្រព្យសំភារៈ ការទូទាត់ជាឥណទេយ្យរបស់រដ្ឋលើ**កសស** ឬការបញ្ចូលធនបំរុងត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយអាចប្រព្រឹត្តទៅបានលុះណាតែមានចែងក្នុងច្បាប់ហិរញ្ញវត្ថុ ។

ការបន្ថែមមូលធនរបស់ **កសស** ដោយភាគទុនជាទ្រព្យសំភារៈ ឬដោយការផាត់ទូទាត់ជាឥណទេយ្យត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការបន្ថែមមូលធនរបស់ **កសស**ដោយភាគទុនជារូបិយវត្ថុ អាចស្នើឡើងដោយក្រុមប្រឹក្សាភិបាលលុះត្រាណាតែភាគហ៊ុនជារូបិយវត្ថុទាំងមូលត្រូវបានបង់គ្រប់ចំនួន ។

ការបន្ថែមមូលធនអាចប្រព្រឹត្តតាមការតំឡើងតម្លៃភាគហ៊ុន និងដោយការបញ្ចេញភាគហ៊ុនថ្មីបន្ថែម ។ ៦

ការបន្ថែមមូលធនត្រូវស្ថិតក្រោមទំរង់ការផ្សព្វផ្សាយជាសាធារណៈ និងរបបសារពើពន្ធអនុវត្តចំពោះក្រុមហ៊ុនពាណិជ្ជកម្ម ។

## ប្រការ ៨ : ការបន្ថយមូលធន

ការបន្ថយមូលធនត្រូវសំរេចដោយក្រុមប្រឹក្សាភិបាល និងត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការបន្ថយមូលធនអាចប្រព្រឹត្តទៅបានក្នុងករណីទូទាត់ជំរះនូវការខាតបង់ដែលពិនិត្យឃើញរបស់**កសស**ក្រោយពីមានការកាត់យកពីប្រាក់បំរុង ។ មូលធនមិនអាចបន្ថយអោយក្រោមពីចំនួនអប្បបរមាតាមច្បាប់ដែលមានចែងដោយច្បាប់សំរាប់ក្រុមហ៊ុនពាណិជ្ជកម្ម ។

ការបន្ថយមូលធនធ្វើឡើងដោយការបន្ថយតម្លៃនៃភាគហ៊ុន ឬការបន្ថយចំនួនភាគហ៊ុន ។

ការបន្ថយមូលធនត្រូវស្ថិតនៅក្រោមទម្រង់ការផ្សព្វផ្សាយជាសាធារណៈនិងរបបសារពើពន្ធដែលអនុវត្តចំពោះក្រុមហ៊ុនពាណិជ្ជកម្ម។

## ប្រការ ៩ : ការចុះឈ្មោះ និងការបង់ភាគហ៊ុន

### ក- ការចុះឈ្មោះ

មូលធនដំបូងរបស់ **កសស** ត្រូវចុះឈ្មោះទាំងស្រុងមុនការចុះហត្ថលេខាក្នុងបញ្ជីពាណិជ្ជកម្ម ។ ការចុះឈ្មោះត្រូវមានសំគាល់ដោយបណ្ណ័ចុះឈ្មោះដែលចុះហត្ថលេខា ដោយអាណត្តិគាហកៈរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ។ ភាគទុនជាទ្រព្យសំភារៈត្រូវជាកម្មវត្ថុនៃការវាយតំលៃរបស់គណកម្មការមួយដែលត្រូវរៀបចំបញ្ជីសារពើភណ្ឌ័ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរាប់ដាក់ភ្ជាប់ជាឧបសម្ព័ន្ធជាមួយលក្ខន្តិកៈ ។

ការចុះឈ្មោះសំរាប់ការបន្ថែមមូលធន ត្រូវមានសំគាល់ដោយបណ្ណ័ចុះឈ្មោះដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។ ការបន្ថែមមូលធនតាមភាគហ៊ុនជាទ្រព្យសំភារៈត្រូវស្ថិតក្រោមទំរង់ការដែលមានពណ៌នាក្នុងកថាខណ្ឌ័មុន ។

### ខ- ការបង់ភាគហ៊ុន

ចំនួនទឹកប្រាក់ដែលបានចុះឈ្មោះអាចត្រូវបង់តាមករណីនីមួយៗ ដោយការបង់ជាសាច់ប្រាក់ឬប្រភេទដូចគ្នាតាមភាគទុនជាទ្រព្យសំភារៈ តាមការទូទាត់ជាឥណទេយ្យរបស់រដ្ឋទៅលើ**កសស** ឬតាមការបញ្ចូលធនបំរុង ។

### ខ.១- ការបង់ជាសាច់ប្រាក់ ឬប្រភេទដូចគ្នា

ការចុះឈ្មោះនៃមូលធនដំបូង ឬការបន្ថែមមូលធនត្រូវបង់រូបិយវត្ថុ។ ភាគហ៊ុនត្រូវបង់នៅពេលចុះឈ្មោះយ៉ាងតិចចំនួន ១/៤ នៃទឹកប្រាក់សរុប ហើយការបង់គ្រប់ចំនួនទាំងអស់ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាង យូរ ៣ ឆ្នាំ ។

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬអាណត្តិគាហកៈត្រូវដឹកលំមូលនិធិលើគណនីមួយនៅធនាគារជាតិ ឬធនាគារជាតិកម្ពុជា ។ ការដាក់ប្រាក់ត្រូវមានកំណត់សំគាល់ដោយលិខិតយុត្តិកាបញ្ជាក់ចេញដោយអ្នកទទួលរក្សាប្រាក់ទុក ។ មូលនិធិត្រូវហាមមិនអោយដកប្រើប្រាស់ ។

ចំពោះការចុះឈ្មោះដំបូងរហូតដល់ពេលបំពេញទំរង់ការតាមច្បាប់សំរាប់ការចុះលេខនៃ **កសស** ។ ៤

ចំពោះការបន្ថែមមូលធនរហូតដល់ពេលបំពេញទំរង់ការតាមច្បាប់សំរាប់ផ្សព្វផ្សាយជាសាធារណៈ ។

**៩.២- ភាគទុនជាសំភារៈ**

ភាគទុនជាទ្រព្យសំភារៈត្រូវបង់ទាំងស្រុងនៅពេលបញ្ចេញ ក្នុងខណៈរៀបចំបង្កើត **កសស** ឬក្នុងខណៈធ្វើការបន្ថែមមូលធន ។

**៩.៣- ការទូទាត់ជាឥណទេយ្យរបស់រួយលើ កសស**

ក្នុងករណីបន្ថែមមូលធនដោយការទូទាត់ជាឥណទេយ្យ ការបង់ភាគហ៊ុនដែលចុះឈ្មោះត្រូវធ្វើឡើងតាមការបំពេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវទំរង់បែបបទរដ្ឋបាលទាក់ទងដល់ប្រតិបត្តិការនេះ និងតាមការចុះនាមប្រតិបត្តិការក្នុងគណនីរបស់ **កសស** ។

**៩.៤- ការបញ្ចូលធនបំរុង**

ក្នុងករណីបន្ថែមមូលធនដោយការបញ្ចូលធនបំរុង ប្រតិបត្តិការអាចធ្វើឡើងតាមការចុះនាមក្នុងគណនីរបស់ **កសស** ។

## ប្រការ ១០ : ការផ្ទេរកម្មសិទ្ធិនៃភាគហ៊ុន

សេចក្ដីសំរេចផ្ទេរកម្មសិទ្ធិនៃភាគហ៊ុនទាំងមូលឬតាមផ្នែករបស់ **កសស** និងអាចធ្វើឡើងតាមអនុក្រឹត្យប៉ុណ្ណោះ តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីមានការអនុម័តពីក្រុមប្រឹក្សាភិបាល ។

# ជំពូកទី ៣

# ក្រុមប្រឹក្សាភិបាល

## ប្រការ ១១ : សមាសភាពក្រុមប្រឹក្សាភិបាល

**កសស** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខណ្ឌស្វយ័តភាព និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

សមាសភាពក្រុមប្រឹក្សាភិបាលរួមមាន :

- ប្រធានអគ្គនាយក កសស ១រូប
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ១រូប
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប
- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប
- តំណាងអាជ្ញាធរក្រុងព្រះសីហនុ ១រូប
- តំណាងក្រសួងពាណិជ្ជកម្ម ១រូប
- តំណាងនិយោជិតរបស់ កសស ១រូប ៤

## ប្រការ ១២ : ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្មធ្លាប់បានបំរើការងារយ៉ាងតិច ៥ ឆ្នាំ ( ប្រាំ ) ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្ម ព្រហ្មទណ្ឌក៏រតចូនពីតុលាការឡើយ ។

អាណត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាលអាចបន្តទៀតបាន អាចត្រូវបញ្ឈប់ពីអាណត្តិរបស់ខ្លួនគ្រប់កាលៈទេសៈដោយអនុក្រឹត្យតាមសំណើរបស់អាជ្ញាធរដែលខ្លួនតំណាងអោយ ។

ក្នុងករណីដែលមានតំណែងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់នៅទំនេរ អាជ្ញាធររបស់សមាជិកនោះត្រូវផ្តល់ឈ្មោះអ្នកជំនួសទៅជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងរយៈពេល ១៥ ថ្ងៃក្រោយពិនិត្យឃើញភាពទំនេរនេះ ។

តំណែងទំនេរ ត្រូវដាក់បំពេញសំរាប់អាណត្តិរយៈពេលដែលនៅសល់ក្នុងអាណត្តិដោយអនុក្រឹត្យ តាមការស្នើសុំពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

### ក- សមាជិកស្វយ័តប្រវត្តិនៃក្រុមប្រឹក្សាភិបាល

តំណាងនិយោជិតត្រូវជ្រើសរើសដោយការបោះឆ្នោតសំរាប់រយៈពេល ៣ ( បី ) ឆ្នាំ តាមនីតិវិធីដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។ អាណត្តិរបស់តំណាងនិយោជិតអាចបន្តជាថ្មីទៀតបាន ។ តំណាងនិយោជិតត្រូវស្ថិតនៅក្នុងក្រុមប្រឹក្សាភិបាលអាចចូលរួមបានដោយពុំចាំបាច់អោយសច្ចាប័នដោយអនុក្រឹត្យទេ ។

ក្នុងករណីតំណាងនិយោជិតអវត្តមានរយៈពេល ៣ ខែដោយមូលហេតុអ្វីក៏ដោយតំណាងបំរុងត្រូវជំនួសដោយស្វ័យប្រវត្តិ ។

អាណត្តិរបស់តំណាងនិយោជិត ត្រូវបញ្ចប់នៅថ្ងៃដែលតំណាងថ្មីត្រូវបានតែងតាំងក្រោយពីការបោះឆ្នោតជ្រើសរើសរួច ។

### ខ- ប្រធានក្រុមប្រឹក្សាភិបាល

- ប្រធានអគ្គនាយក ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ **កសស** ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់រយៈពេលនៃអាណត្តិសមាជិកក្រុមប្រឹក្សាភិបាលរបស់ខ្លួន ដោយរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

អាណត្តិរបស់ប្រធានក្រុមប្រឹក្សាភិបាលអាចបន្តទៀតបានដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

- ប្រធានក្រុមប្រឹក្សាភិបាលកោះអញ្ជើញសមាជិកក្រុមប្រឹក្សាភិបាល និងកំណត់របៀបវារៈហើយចាត់ចែងការងារអោយមានដំណើរការល្អ ។

- ប្រធានក្រុមប្រឹក្សាភិបាលអាចបញ្ឈប់បានគ្រប់ពេលវេលាពីអាណត្តិដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ប្រការ ១៣ : វិសមតិភាព

សមាជិកក្រុមប្រឹក្សាភិបាលពុំអាចមានអាណត្តិជាអ្នកតំណាងរាស្ត្រ ឬមុខងារក្នុងរាជរដ្ឋាភិបាលបានឡើយ ។៤

**ប្រការ ១៤ : ការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សាភិបាល**

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដែលបណ្តាលមកពីការបំពេញភារកិច្ចជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ **កសស** ត្រូវជាបន្ទុករបស់រដ្ឋ ។

- ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ គឺសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗជាអ្នកទទួលខុសត្រូវផ្ទាល់ខ្លួន ។
- តំណាងនិយោជិត ត្រូវទទួលខុសត្រូវ តែផ្នែកព្រហ្មទណ្ឌប៉ុណ្ណោះ ។

**ប្រការ ១៥ : ភាគហ៊ុនធានា**

សមាជិកក្រុមប្រឹក្សាភិបាលនៃ **កសស** ត្រូវអនុញ្ញាតអោយរួចពីកាតព្វកិច្ចក្នុងការដាក់ភាគហ៊ុនធានា ។

**ប្រការ ១៦ : លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល**

តាមសំណើរបស់ក្រុមប្រឹក្សាភិបាល **កសស** ប្រកាសរួមមួយរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកំណត់គោលការណ៍ និងលាភការសំរាប់មុខងារសមាជិកក្រុមប្រឹក្សាភិបាលរបស់ **កសស** ។

- ការបើកលាភការអាចត្រូវផ្អាកដោយអាជ្ញាធរដែលជាអ្នកធ្វើសំណើតែងតាំងចំពោះគ្រប់សមាជិកក្រុមប្រឹក្សាភិបាលណាដែលមិនគោរពកាតព្វកិច្ចនៃអាណត្តិរបស់ខ្លួនដូចជា : មិនខុសប្បាហ៍ព្យាយាមក្នុងការងារ មិនគោរពតាមបទបញ្ញត្តិនានាដែលមានចែងក្នុងកិច្ចដំណើរការរបស់ **កសស** មិនការពារនយោបាយ និងផលប្រយោជន៍របស់អាជ្ញាធរដែលតែងតាំងអាណត្តិអោយខ្លួន មិនរាយការណ៍ពីសកម្មភាពដល់អាជ្ញាធរ ឬក្រសួងដែលខ្លួនតំណាងអោយ ។

**ប្រការ ១៧ : អំណាចរបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញដើម្បីសំរេចក្នុងនាម **កសស** ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមានដោយពុំប៉ះពាល់ដល់ការអនុវត្តបទបញ្ញត្តិស្តីពីអាណាព្យាបាលភាពរដ្ឋឡើយ ។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះក្រុមប្រឹក្សាភិបាលត្រូវ :

- ពិនិត្យ និងអនុម័តផែនការអាជីវកម្ម ផែនការអភិវឌ្ឍន៍ និងវិនិយោគរបស់ **កសស**
- ពិនិត្យ និងអនុម័តគំរោងថវិកាប្រចាំឆ្នាំ និងត្រួតពិនិត្យអនុម័តតុល្យការ
- ពិនិត្យ និងអនុម័តគំរោងបែងចែកប្រាក់ចំណេញ ឬគំរោងបំពេញឱនភាពរបស់ **កសស**
- ពិនិត្យផែនការ និងលើកសំណូមពរក្នុងការបង្កើន ឬបន្ថយទុនក្នុងបញ្ជីរបស់ **កសស**
- របាយការណ៍ពីសកម្មភាពការងារ និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការងារចាត់ចែង និងភារកិច្ចទូទៅរបស់ **កសស**
- កំណត់របបផែនការជ្រើសរើស ការតម្លើងឋានៈ និងការផ្តល់លាភការដល់និយោជិត
- សំរេចចំនួនក្របខ័ណ្ឌនិយោជិត ដែលអនុញ្ញាតសំរាប់ **កសស**
- ជ្រើសរើសកំណត់លាភការសំរាប់ផ្តល់អោយស្នងការគណនី
- ធ្វើសំណើកែសំរួលលក្ខន្តិកៈ
- អនុម័តលើលទ្ធកម្មនានា ៤

## ប្រការ ១៨ : ការបែងចែកអំណាច

ក្រុមប្រឹក្សាភិបាលបែងចែកអំណាច អោយទៅប្រធានអគ្គនាយកនូវអំណាច គ្រប់គ្រងទាំងអស់ក្នុង **កសស** ក្នុងការបំពេញការងារប្រចាំថ្ងៃ ។ ការបែងចែកអំណាចនេះពុំមែនជាការផ្ទេរការទទួលខុសត្រូវឡើយ ។

ទម្រង់នៃការបែងចែកអំណាចនេះត្រូវបំពេញដោយក្រុមប្រឹក្សាភិបាលនាសម័យប្រជុំលើកទី ១ ក្រោយពីការបង្កើតរបស់ខ្លួនហើយត្រូវធ្វើកំណត់ហេតុអោយបានច្បាស់លាស់ ។

ក្រុមប្រឹក្សាភិបាល អាចផ្លាស់ប្តូរខ្លឹមសារនៃការបែងចែកអំណាច ដែលត្រូវប្រគល់អោយប្រធានអគ្គនាយក ដោយគោរពតាមបទបញ្ញត្តិនៃមាត្រាទី ១០ និងទី១១ នៃព្រះរាជក្រមលេខ ជស/រកម០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ប្រការ ១៩: ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលត្រូវចូលរួមប្រជុំជាសាមញ្ញយ៉ាងតិច ៣ ខែម្តងហើយអាចប្រជុំជាវិសាមញ្ញរាល់ពេលណាដែលផលប្រយោជន៍របស់ **កសស**តំរូវអោយចាំបាច់ ។

ក្រុមប្រឹក្សាភិបាល ធ្វើការពិភាក្សាសំរេចលើបញ្ហាដែលបានចុះក្នុងរបៀបវារៈ ហើយត្រូវជូនដំណឹងយ៉ាងតិច ១០ថ្ងៃ ជាមុនដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលចូលរួមប្រជុំតាមការផ្តួចផ្តើមរបស់ប្រធាន ឬតាមការស្នើសុំរបស់សមាជិកចំនួន ០៤ នាក់ ឬរបស់ប្រធានអគ្គនាយក ។

លេខាធិការដ្ឋាននៃអង្គប្រជុំក្រុមប្រឹក្សាភិបាលត្រូវធានាដោយប្រធានអគ្គនាយក ។

## ប្រការ ២០ : សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល

ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបានលុះត្រាតែមានសមាជិកភាគច្រើនចូលរួម( ២/៣ឡើងទៅ ) ។ សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់អវត្តមានពុំអាចអោយគេចូលជំនួសបានឡើយ ។

ក្នុងករណីដែលប្រធានអវត្តមាន អង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវដឹកនាំដោយសមាជិកម្នាក់ដែលជ្រើសតាំងដោយសមាជិកមានមុខចូលរួម ។

ករណីការប្រជុំលើកទី ១ ពុំគ្រប់កូរ៉ុម ការកោះអញ្ជើញលើកទី ២ ត្រូវបញ្ជូនក្នុងរយៈពេល១៥ ថ្ងៃបន្ទាប់ ។ ការពិភាក្សាពេលនេះអាចប្រព្រឹត្តទៅបានពុំចាំបាច់តម្រូវពីកូរ៉ុមទេ ហើយពិភាក្សាតែលើរបៀបវារៈដែលបានចុះជាមួយការអញ្ជើញទៅលើកទី ១ ។ ត្រូវមានបញ្ជីវត្តមានដែលមានចុះហត្ថលេខារបស់សមាជិកក្រុមប្រឹក្សាភិបាលដែលបានចូលរួម ។

ការសម្រេចត្រូវអនុម័តយកតាមមតិភាគច្រើនរបស់សមាជិកចូលរួមដោយការលើកដៃ ។ ក្នុងករណីមានសំលេងស្មើគ្នា សំលេងរបស់ប្រធានចាត់ទុកជាឧត្តមានុភាព ។

កិច្ចពិភាក្សា របស់ក្រុមប្រឹក្សាភិបាល ត្រូវបានកត់ត្រាទុកក្នុងសៀវភៅពិសេសមួយរក្សាទុកនៅទីចាត់ការ **កសស** ហើយត្រូវមានចុះហត្ថលេខាដោយប្រធាន និងលេខាធិការនៃអង្គប្រជុំ ។ កំណត់ហេតុប្រជុំត្រូវបញ្ជូន ៤

ក្នុងរយៈពេលយ៉ាងយូរ ១០ថ្ងៃក្រោយពីការប្រជុំ ជូនទៅគ្រប់សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិង ដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

កំណត់ហេតុត្រូវឆ្លុះបញ្ចាំងនូវខ្លឹមសារនៃការពិភាក្សាដេញដោល ។ ករណីមានសំណូមពរ ឬការតវ៉ាពីសមាជិកណាម្នាក់លេខាធិការត្រូវកត់ត្រាចូលក្នុងកំណត់ហេតុ ហើយត្រូវចុះក្នុងរបៀបវារៈសំរាប់ការប្រជុំលើកក្រោយ ។

## ជំពូកទី ៤

## អង្គការប្រតិបត្តិរបស់ កសស

### ប្រការ ២១: ប្រធានអគ្គនាយក

**កសស** ត្រូវបានគ្រប់គ្រងដឹកនាំដោយ ប្រធានអគ្គនាយកដែលតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

ប្រធានអគ្គនាយកអាចត្រូវដកចេញដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

### ប្រការ ២២ : ឋិសមតិភាព

ប្រធានអគ្គនាយក **កសស** មានឋិសមតិភាពជាមួយអ្នកតំណាងរាស្ត្រ ឬមុខងារក្នុងរាជរដ្ឋាភិបាល ។

### ប្រការ ២៣ : ភារកិច្ចរបស់ប្រធានអគ្គនាយក

ប្រធានអគ្គនាយកគឺជាតំណាងរបស់ **កសស** ក្នុងទំនាក់ទំនងជាមួយតតីយជន ។ ប្រធានអគ្គនាយកអាចបំពេញបេសកកម្មក្នុងក្របខណ្ឌនៃការបែងចែកអំណាចដែលចែងក្នុងប្រការទី ១៨ ខាងលើ ។

ក្នុងឋានៈនេះប្រធានអគ្គនាយកមានភារកិច្ច :

- ជាទូទៅគឺមានភារកិច្ចបំពេញមុខងាររដ្ឋបាល និងការគ្រប់គ្រងដែលចាំបាច់ក្នុងដំណើរការធម្មតារបស់ **កសស**
- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកប្រតិបត្តិនូវសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំផែនការថវិកាប្រចាំឆ្នាំ របស់ **កសស** ដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍ សកម្មភាពប្រចាំឆ្នាំព្រមជាមួយគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុមត័ ។
- បំពេញតំណែងរបស់ **កសស** ក្នុងកំរិតកំណត់នៃចំនួនក្របខណ្ឌបុគ្គលិកដែលសំរេចដោយក្រុមប្រឹក្សាភិបាល និងដោយគោរពតាមវិធានការគ្រប់គ្រងបុគ្គលិក
- អនុវត្តឋានានុក្រមរបស់អាជ្ញាធរចំពោះបុគ្គលិកទាំងអស់
- សំរេចលើកិច្ចសន្យា និងចុះហត្ថលេខាលើអនុសញ្ញាដោយអនុលោមតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការបែងចែកអំណាច ៤

# ជំពូកទី ៥
## មហាសន្និបាត

### ប្រការ ២៤ : មហាសន្និបាត

**កសស** ដំណើរការដោយគ្មានមហាសន្និបាតរបស់ម្ចាស់ភាគហ៊ុន ។ អំណាចដែលត្រូវបានប្រគល់ដោយច្បាប់ស្តីពីក្រុមហ៊ុនពាណិជ្ជកម្មដល់មហាសន្និបាតរបស់ម្ចាស់ភាគហ៊ុនត្រូវអនុវត្តដោយក្រុមប្រឹក្សាភិបាល ។

# ជំពូកទី ៦
## ការគ្រប់គ្រង កសស

### ប្រការ ២៥ : អំពីទ្រព្យសម្បត្តិ

- **កសស** គឺជាអ្នកចាត់ចែងលើទ្រព្យសម្បត្តិដែលរដ្ឋបានប្រគល់អោយ ។ នៅក្នុងខណៈនេះ **កសស** ទទួលបន្ទុកគ្រប់គ្រង ថែរក្សា តាមបណ្តាគោលការណ៍ដែលបានកំណត់ ។
- **កសស** ត្រូវចុះបញ្ជីសារពើភណ្ឌដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ បញ្ជីសារពើភណ្ឌនេះត្រូវកំណត់ចូលក្នុងបញ្ជីគណនេយ្យរបស់សហគ្រាស ហើយត្រូវបានកំណត់ក្នុងតារាងតុល្យការដំបូង ។
- **កសស** រៀបចំចាត់ចែងទ្រព្យសម្បត្តិផ្ទាល់ដែលមាន និងគ្រប់គ្រងអោយស្របតាមច្បាប់ និងបទបញ្ញត្តិក៏ដូចជាតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

### ប្រការ ២៦ : និយោជិត

និយោជិតរបស់ **កសស** មានក្របខណ្ឌជានិយោជិតនៃនិតិឯកជន លើកលែងតែមន្ត្រីដែលបំពេញតួនាទីដឹកនាំ : ប្រធានអគ្គនាយក ។ និយោជិតត្រូវគ្រប់គ្រងដោយបទបញ្ជាផ្ទៃក្នុងរបស់និយោជិតដែលបានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។

### ប្រការ ២៧ : វិធាននៃការគ្រប់គ្រង

ការគ្រប់គ្រង **កសស** ត្រូវអនុលោមតាមវិធាន និងច្បាប់ទម្លាប់ពាណិជ្ជកម្ម ។ ទំនាក់ទំនង **កសស** ជាមួយតតិយជនត្រូវស្ថិតក្រោមបទបញ្ញត្តិអនុវត្តចំពោះក្រុមហ៊ុនពាណិជ្ជកម្ម និងពាណិជ្ជកិច្ច ។

### ប្រការ ២៨ : ផែនការហិរញ្ញវត្ថុ

ការគ្រោងទុកជាមុននូវចំណូល និងចំណាយរបស់ **កសស** ត្រូវមានចែងក្នុងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំសំរាប់ការប្រព្រឹត្តទៅ និងវិនិយោគរបស់ **កសស** ។ ផែនការហិរញ្ញវត្ថុនេះត្រូវបានរៀបចំដោយប្រធានអគ្គនាយក ហើយដាក់ជូនក្រុមប្រឹក្សាភិបាលធ្វើការអនុមត័យ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែកញ្ញា នៃឆ្នាំទីមួយ១ ។

## ប្រការ ២៩: គណនីរបស់ កសស

ការិយបរិច្ឆេទរបស់ **កសស** ត្រូវចាប់ផ្តើមពីថ្ងៃទី ០១ ខែមករា ហើយត្រូវបញ្ចប់នៅថ្ងៃ ៣១ ខែធ្នូជារៀងរាល់ឆ្នាំ ។ ក្នុងករណីលើកលែងការិយបរិច្ឆេទទី ១ចាប់ផ្តើមនៅថ្ងៃចុះលេខរបស់ **កសស** ក្នុងបញ្ជីពាណិជ្ជកម្ម ហើយត្រូវបញ្ចប់នៅថ្ងៃ ៣១ ខែ ធ្នូ ។

គណនេយ្យ **កសស** ត្រូវដាក់អោយកាន់កាប់ហើយប្រតិបត្តិការគណនេយ្យត្រូវអនុវត្តតាមច្បាប់ទំលាប់ពាណិជ្ជកម្មដោយអនុលោមតាមប្លង់គណនេយ្យជាតិ ។

ក្រោយចប់ការិយបរិច្ឆេទនីមួយៗ ប្រធានអគ្គនាយកត្រូវរៀបចំឯកសារសំរាប់ដាក់ជូនក្រុមប្រឹក្សាភិបាលសំរេចនូវ :

- បញ្ជីសារពើភណ្ឌចលនទ្រព្យ និងអចលនទ្រព្យដែលជាទ្រព្យសម្បត្តិរបស់ **កសស** ។
- តុល្យការ គណនីលទ្ធផល និងឧបសម្ព័ន្ធដោយអនុលោមតាមបទបញ្ញត្តិនៃអត្ថបទដែលគ្រប់គ្រងលើបញ្ហានេះ ។
- ឯកសារទាំងនេះ ត្រូវមានភ្ជាប់ជាមួយរបាយការណ៍សកម្មភាពការងារដែលត្រូវរៀបចំ និងបង្ហាញដោយ ប្រធានអគ្គនាយកផងដែរ ។
- គណនីប្រចាំឆ្នាំត្រូវអនុមត័ដោយក្រុមប្រឹក្សាភិបាលក្នុងរយៈពេល ០៣ ខែយ៉ាងយូរ បន្ទាប់ពីការបិទការិយបរិច្ឆេទនៃ **កសស** ។

**កសស**ត្រូវអនុវត្តតាមទំរង់ការដែលមានគ្រោងទុកចំពោះក្រុមហ៊ុនពាណិជ្ជកម្ម ក្នុងបញ្ហាផ្សព្វផ្សាយគណនីក្រុមហ៊ុនជាសាធារណៈ ។

## ប្រការ ៣០ : ការបែងចែកប្រាក់ចំណេញ

ក្រោយពីបានអនុម័តលើគណនីបើពិនិត្យឃើញថាមានចំណេញ ក្រុមប្រឹក្សាភិបាលនៃ **កសស** អាចសំរេចផ្ទេរទឹកប្រាក់ទាំងនោះដើម្បី :

១- កាត់ទូទាត់នូវការខាតបង់កាលពីការិយបរិច្ឆេទមុន ។

២-ក្រោយពីបានទូទាត់នូវការខាតបង់កាលពីការិយបរិច្ឆេទមុនហើយ ប្រសិនបើនៅមានប្រាក់ចំណេញនោះក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ប្រាក់ចំណេញនេះសំរាប់ :

ក- ថ្លៃងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិតតាមលក្ខខណ្ឌ :

- ករណីប្រាក់ចំណេញនៅសល់មានចំនួនពី ៥ % ទៅ ១០ % នៃចំណាយសហគ្រាសរបស់ **កសស** ប្រចាំឆ្នាំ នោះត្រូវថ្លៃងសសើរស្មើ ០១ ខែនៃប្រាក់បៀវត្ស ។
- ករណីប្រាក់ចំណេញនៅសល់មានចំនួនពី ១១ % ទៅ ២០ % នៃចំណាយសហគ្រាសរបស់ **កសស** ប្រចាំឆ្នាំ នោះត្រូវថ្លៃងសសើរស្មើ ០២ ខែនៃប្រាក់បៀវត្ស ។
- ករណីប្រាក់ចំណេញលើសពី ២១ % នៃចំណាយសហគ្រាសរបស់ **កសស** ប្រចាំឆ្នាំ នោះត្រូវថ្លៃងសសើរស្មើ ០៣ ខែនៃប្រាក់បៀវត្ស ។ ៤

ខ- បង្កើតមូលនិធិបំរុងតាមច្បាប់ ៥%។

គ- បង្កើតមូលនិធិបំរុងសេរីចំនួន ៥%។

ឃ- បង្កើតមូលនិធិបេឡាសោធននិវត្តន៍ ។

ង- ប្រាក់ដែលនៅសល់ត្រូវបង្កើតមូលនិធិអភិវឌ្ឍន៍សហគ្រាស ។

**ប្រការ ៣១: ការបែងចែកការខាតបង់របស់ កសស**

ករណីមានការខាតបង់ក្រុមប្រឹក្សាភិបាលអាច :

- ទុកការខាតបង់នេះនៅក្នុងគណនីយោងទៅការិយបរិច្ឆេទថ្មី ។
- កាត់ដកចេញពីគណនីធនបំរុង ។

បើការខាតបង់ដែលបានពិនិត្យឃើញធ្វើអោយមូលធនជាក់ស្តែងរបស់ **កសស**ធ្លាក់ចុះក្រោម ៣/៤ នៃមូលធនដើម ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំដើម្បីធ្វើសំណើទៅរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមួយសុំរំសាយ **កសស** ឬមួយដាក់ផែនការរៀបចំរចនាសម្ព័ន្ធជាថ្មីដែលអាចបន្តធ្វើអាជីវកម្ម។ ការសំរេចចុងក្រោយស្ថិតជាសមត្ថកិច្ចរបស់គណរដ្ឋមន្ត្រី តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៣២ : របបសារពើពន្ធ និងពន្ធគយ**

**កសស** ត្រូវស្ថិតក្រោមរបបរួមស្តីពីសារពើពន្ធហើយត្រូវជាប់ពន្ធ និងអាករដូចក្រុមហ៊ុនពាណិជ្ជកម្ម ។

**ប្រការ ៣៣ : កិច្ចសន្យា**

ការផ្ទេរការអនុវត្ត និងការត្រួតពិនិត្យកិច្ចសន្យា **កសស** ត្រូវគ្រប់គ្រងដោយបទបញ្ញត្តិនៃមាត្រាទី ១៨ និង ១៩ នៃព្រះរាជក្រមលេខ : ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈសហគ្រាសសាធារណៈ ។

**ប្រការ ៣៤ : អំពីលទ្ធកម្មរបស់ កសស**

ការគ្រប់គ្រងលទ្ធកម្មនៅ **កសស** ត្រូវគោរពតាមប្រកាសលេខ ៩៩៧ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងលទ្ធកម្មនៅសហគ្រាសសាធារណៈ ។

## ជំពូកទី ៧

## អាណាព្យាបាលភាព

**ប្រការ ៣៥ : ទំនាក់ទំនងផ្តល់ឯកសារ**

ប្រធានអគ្គនាយក **កសស** ត្រូវផ្តល់ជូនគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យរដ្ឋ នូវឯកសារដូចតទៅ :

- កំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សាភិបាល ។
- ថវិកាសំរាប់ដំណើរការ និងការវិនិយោគរបស់ **កសស** ។ ៤

- របាយការណ៍សកម្មភាពការងារ តារាងតុល្យការ គណនីលទ្ធផល និងឯកសារជាឧបសម្ព័ន្ធ ។
- របាយការណ៍របស់សួងការគណនីស្របច្បាប់ ។

## ផ្នែកទី ១ : អាណាព្យាបាលភាពបច្ចេកទេស

### ប្រការ ៣៦ : សិទ្ធិអនុមតថវិកា

គំរោងថវិការប្រចាំឆ្នាំសំរាប់ដំណើរការ និងវិនិយោគរបស់ **កសស** ត្រូវបានទទួលការយល់ព្រមដោយ រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមលក្ខខណ្ឌកំណត់ ដោយច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអត្ថបទច្បាប់បន្តបន្ទាប់ទៀត ។

### ប្រការ ៣៧ : សិទ្ធិជំទាស់

រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អាចធ្វើការជំទាស់ទៅលើឯកសារដូចដែលត្រូវបានបញ្ជូនមក ដោយអនុវត្តតាមបទបញ្ញត្តិនៃប្រការ ៣៥ ខាងលើដូចជា : កំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សា ភិបាល របាយការណ៍សកម្មភាពការងារ តារាងតុល្យការ គណនីលទ្ធផល ព្រមជាមួយឧបសម្ព័ន្ធរបាយការណ៍ផ្ទៀង ផ្ទាត់របស់សួងការគណនីស្របច្បាប់ ។

ការជំទាស់នេះត្រូវធ្វើតាមលក្ខខណ្ឌកំណត់ដោយព្រះរាជក្រមលេខ : ជស/រកម /០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអត្ថបទ បន្តបន្ទាប់ផ្សេងទៀត ។

### ប្រការ ៣៨ : អគ្គាធិការដ្ឋានបច្ចេកទេស

**កសស** ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យបច្ចេកទេសដោយ អគ្គាធិការដ្ឋានក្រសួងសាធារណការ និង ដឹកជញ្ជូន ក្នុងករណីចាំបាច់ ។

## ផ្នែកទី ២ : អាណាព្យាបាលភាពហិរញ្ញវត្ថុ

### ប្រការ ៣៩ : មន្ត្រីត្រួតពិនិត្យរដ្ឋ

ត្រូវចាត់អោយនៅអម **កសស** នូវមន្ត្រីត្រួតពិនិត្យរដ្ឋមួយរូបដែលត្រូវបានតែងតាំង ដោយអនុក្រឹត្យតាម សំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុម ប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំលេងអនុម័តឡើយ ។ មន្ត្រីត្រួត ពិនិត្យរដ្ឋត្រូវបំពេញមុខងារក្នុងលក្ខខណ្ឌដែលមានកំណត់ក្នុងមាត្រា២០ ដល់២៥ របស់ព្រះរាជក្រមលេខ : ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអត្ថបទបទបញ្ជាដាក់សំរាប់ការអនុវត្តច្បាប់នេះ ។

### ប្រការ ៤០ : សួងការគណនី

គណនីរបស់ **កសស** ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទៀងផ្ទាត់ ថវិកាប្រចាំឆ្នាំ ដោយសួងការគណនី ដែលត្រូវតែងតាំង និងបំពេញ បេសកកម្មក្នុងលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា ១៧ នៃព្រះរាជក្រមលេខ : ជស/រកម/០៦៩៦/០៣ ចុះថ្ងៃ ទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងអត្ថបទបញ្ជាសំរាប់ ការអនុវត្តច្បាប់នេះ ។ ៤

**ប្រការ ៤១ : អគ្គាធិការដ្ឋានហិរញ្ញវត្ថុ**

**កសស** ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យហិរញ្ញវត្ថុដោយអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីចាំបាច់ ។

**ប្រការ ៤២ : ភាពនៅរួមគ្នាក្នុងបញ្ជីទ្រព្យរដ្ឋ**

**កសស** ត្រូវស្ថិតនៅក្នុងបញ្ជីទ្រព្យសម្បត្តិរដ្ឋ ។ ក្នុងន័យនេះ **កសស** ត្រូវស្ថិតនៅក្រោមវិធានដែលកំណត់ពីបញ្ហាគ្រប់គ្រងបញ្ជីទ្រព្យសម្បត្តិរដ្ឋតាមព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអត្ថបទបន្តបន្ទាប់ផ្សេងៗទៀត ។

## ជំពូកទី ៨

## ការរំលាយបញ្ចូលគ្នា បំបែក ជំរះបញ្ជី ឬឯកជនភាវូបនីយកម្មនៃ កសស

**ប្រការ ៤៣ : ការរំលាយចូលគ្នា បំបែក ឬជំរះបញ្ជី**

ការរំលាយបញ្ចូលគ្នា បំបែក ឬជំរះបញ្ជីនៃ **កសស** ត្រូវសំរេចដោយអនុក្រឹត្យតាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយពីមានការផ្តល់មតិពីក្រុមប្រឹក្សាភិបាល ។

**ប្រការ ៤៤: ឯកជនភាវូបនីយកម្ម**

ការធ្វើឯកជនភាវូបនីយកម្មរបស់ កសស ត្រូវមានការអនុញ្ញាតដោយអនុក្រឹត្យតាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោយការផ្តល់មតិពីក្រុមប្រឹក្សាភិបាល ។

ការធ្វើឯកជនភាវូបនីយកម្មនៃ កសស ត្រូវស្ថិតនៅក្រោមច្បាប់ ឬបទបញ្ញត្តិស្តីពីឯកជនភាវូបនីយកម្មនៃសហគ្រាស និងសកម្មទ្រព្យរបស់រដ្ឋ ។

## ជំពូកទី ៩

## ការកែសំរួលលក្ខន្តិកៈ

**ប្រការ ៤៥: ការកែសំរួលលក្ខន្តិកៈ**

លក្ខន្តិកៈរបស់**កសស** អាចធ្វើការកែសំរួលបានគ្រប់ពេលវេលាតាមសំណើសុំពីក្រុមប្រឹក្សាភិបាលដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០១

**ជ.រដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ឃី តាំងលីម**